# ព្រឹត្តិបត្រពាណិជ្ជកម្ម
# iTrade Bulletin

វ៉ុល០២ | លេខពិសេស | ខែតុលា ឆ្នាំ២០២២
VOLUME 02 | SPECIAL EDITION | OCTOBER 2022



**Infographic**
"CAMBODIA: Economic Indicator in RCEP"

**Aide-mémoire**
"Cambodia's Readiness for RCEP"
*TAT Puthsodary & CHAM Nimul*

**Trade Policy Brief**
"New Dynamism of East Asia and ASEAN:
New Trade Institutions in FTAs and 'Living Agreement' of RCEP"
*Prof. Dr. SHANDRE MUGAN THANGAVELU*
*Jeffrey Cheah Institute for Southeast Asia, Sunway University*

# ព្រះរាជាណាចក្រកម្ពុជា
## សូចនាករសេដ្ឋកិច្ចក្នុងអាសិប

រៀបចំដោយ

សូមស្កេនដើម្បីទាញយកព្រឹត្តិបត្រពាណិជ្ជកម្ម




### ពាណិជ្ជកម្មទំនិញ
លុបបំបាត់ពន្ធលើទំនិញជាង ៩០% នៃការជួញដូរក្នុងរយៈពេល ២០ ឆ្នាំ

### វិធានប្រភពដើមទំនិញ
ផ្តល់ឱ្យក្រុមហ៊ុននូវភាពបត់បែនបន្ថែមទៀតចំពោះប្រភពនៃវត្ថុធាតុនាំចូលពីប្រទេសសមាជិកអាសិប ជាមួយនឹងអត្រាពន្ធទាប

### ការចល័តកម្លាំងពលកម្ម
រំហូរពលកម្មឆ្លងព្រំដែនបណ្តោះអាសន្នសម្រាប់សេវាកម្ម និងសកម្មភាពអាជីវកម្មផ្សេងៗ

### នីតិវិធីគយ និង ការសម្រួលពាណិជ្ជកម្ម
សំណុំឯកសារច្បាប់តែមួយសម្រាប់សង្គតិភាពក្នុងការអនុវត្តពាណិជ្ជកម្ម និងគយ ដែលនាំឱ្យមានប្រសិទ្ធភាពកាន់តែប្រសើរឡើង

### ពាណិជ្ជកម្មសេវាកម្ម
យ៉ាងតិចណាស់ ៦៥% នៃវិស័យសេវាកម្មរបស់ប្រទេសអាសិប នឹងបើកចំហយ៉ាងពេញលេញ ជាមួយនឹងតម្លាភាពកាន់តែប្រសើរនៃបទប្បញ្ញត្តិ និងវិធានការ

### ពាណិជ្ជកម្មអេឡិចត្រូនិក និងពាណិជ្ជកម្មឌីជីថល
ផ្តល់ជូននូវបទប្បញ្ញត្តិបន្ថែមទៀតទាក់ទងនឹងពាណិជ្ជកម្មអេឡិចត្រូនិក សំដៅបង្កើនកម្រិតនៃការជឿទុកចិត្ត និងទំនុកចិត្តរបស់អ្នកប្រើប្រាស់

(ប្រភព៖ ITC, World Bank, IMF, UNCTAD, AMRO Staff)

# ពាណិជ្ជកម្មកម្ពុជា

## ពាណិជ្ជកម្មសរុបរបស់កម្ពុជា (មករា-កញ្ញា ២០២២)

**២៤.០៦៦,៣៣ លានដុល្លារ**

| | | | |
|---|---|---|---|
| ៤០៤,៤៦ លានដុល្លារ | ១,៦៨% | ៤៥៤,៧២ លានដុល្លារ | ១,៨៩% |
| ១៤,៧៧ លានដុល្លារ | ០,០៦% | ១៩ លានដុល្លារ | ០,០៨% |
| ៨.៧៩៦,០១ លានដុល្លារ | ៣៦,៥៥% | ៣២,២៤ លានដុល្លារ | ០,១៣% |
| ៦៨១,២៥ លានដុល្លារ | ២,៨៣% | ៨៤,១៥ លានដុល្លារ | ០,៣៥% |
| ១.៤៩៩,៥០ លានដុល្លារ | ៦,២៣% | ៣.០៥៦,១២ លានដុល្លារ | ១២,៧០% |
| ៦០០,៤៣ លានដុល្លារ | ២,៤៩% | ៣.៦២៦, ៩៨ លានដុល្លារ | ១៥,០៧% |
| ១៦២,៩៨ លានដុល្លារ | ០,៦៨% | ៤.៦៣៣,៦៦ លានដុល្លារ | ១៩,២៥% |

(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា)

# សន្ធិសញ្ញាវិនិយោគទ្វេភាគីរបស់កម្ពុជា

**សន្ធិសញ្ញាវិនិយោគទ្វេភាគី កម្ពុជា-ឡាវ**
ចុះហត្ថលេខា៖
ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨
មិនទាន់ចូលជាធរមាន

**សន្ធិសញ្ញាវិនិយោគទ្វេភាគី កម្ពុជា-ជប៉ុន**
ចុះហត្ថលេខា៖
ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៧
ចូលជាធរមាន៖
ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០០៨

**សន្ធិសញ្ញាវិនិយោគទ្វេភាគី កម្ពុជា-វៀតណាម**
ចុះហត្ថលេខា៖
ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០១
ចូលជាធរមាន៖
ថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០០៥

**សន្ធិសញ្ញាវិនិយោគទ្វេភាគី កម្ពុជា-ហ្វីលីពីន**
ចុះហត្ថលេខា៖
ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០០
មិនទាន់ចូលជាធរមាន

**សន្ធិសញ្ញាវិនិយោគទ្វេភាគី កម្ពុជា-ឥណ្ឌូនេស៊ី**
ចុះហត្ថលេខា៖
ថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩
បានបញ្ចប់៖
ថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៦

**សន្ធិសញ្ញាវិនិយោគទ្វេភាគី កម្ពុជា-សា.កូរ៉េ**
ចុះហត្ថលេខា៖
ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៧
ចូលជាធរមាន៖
ថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៧

**សន្ធិសញ្ញាវិនិយោគទ្វេភាគី កម្ពុជា-សិង្ហបុរី**
ចុះហត្ថលេខា៖
ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩៦
ចូលជាធរមាន៖
ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០០

**សន្ធិសញ្ញាវិនិយោគទ្វេភាគី កម្ពុជា-ចិន**
ចុះហត្ថលេខា៖
ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៦
ចូលជាធរមាន៖
ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០០

**សន្ធិសញ្ញាវិនិយោគទ្វេភាគី កម្ពុជា-ថៃ**
ចុះហត្ថលេខា៖
ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៥
ចូលជាធរមាន៖
ថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៩៧

**សន្ធិសញ្ញាវិនិយោគទ្វេភាគី កម្ពុជា-ម៉ាឡេស៊ី**
ចុះហត្ថលេខា៖
ថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៤
ចូលជាធរមាន៖
ថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៩៧

(ប្រភព៖ UNCTAD International Investment Agreements Navigator)




# CAMBODIA

## Economic Indicator in RCEP

Organized by

Please scan to download iTrade Bulletin

### Trade in Goods

Eliminates tariffs on more than 90% of goods traded over a 20-year period

### Rules of Origin

Give firms more flexibility to source inputs from the bloc, while benefitting from low tariffs

### Labor Mobility

Temporary cross-border labor flow for services, other business activities

### Customs Procedures and Trade Facilitation

Single set of rules for greater consistency in trade and customs practices, leadeing to greater efficiency

### Trade in Services

At least 65% of RCEP countries' services sector will be fully open, with greater transparency of regulations and measures

### E-commerce and Digital Trade

Offers more provisions relating to e-commerce, aimed at increasing the level of trust and confidence of users

(Source: ITC, World Bank, IMF, UNCTAD, AMRO Staff)

# CAMBODIA'S TRADE

## Cambodia's Total Trade 2022 (Jan-Sep)

**$ 24,066.33 million**

| | | | |
|---|---|---|---|
| $ 404.46 milion | 1.68% | $ 454.72 million | 1.89% |
| $ 14.77 million | 0.06% | $ 19.00 million | 0.08% |
| $ 8,796.01 million | 36.55% | $ 32.24 million | 0.13% |
| $ 681.25 million | 2.83% | $ 84.15 million | 0.35% |
| $ 1,499.50 million | 6.23% | $ 3,056.12 million | 12.70% |
| $ 600.43 million | 2.49% | $ 3,626.98 million | 15.07% |
| $ 162.98 million | 0.68% | $ 4,633.66 million | 19.25% |

(Source: General Directorate of Customs and Excise of Cambodia)

# CAMBODIA'S BILATERAL INVESTMENT TREATIES



**LAO PDR**
**Cambodia-Lao PDR BIT**
**Signed:** Nov 24, 2008
**Not in force**



**JAPAN**
**Cambodia-Japan BIT**
**Signed:** Jun 14, 2007
**In force:** Jul 31, 2008



**VIET NAM**
**Cambodia-Viet Nam BIT**
**Signed:** Sep 01, 2001
**In force:** Oct 24, 2005



**PHILIPPINES**
**Cambodia-Philippines BIT**
**Signed:** Aug 16, 2000
**Not in force**



**INDONESIA**
**Cambodia-Indonesia BIT**
**Signed:** Mar 16, 1999
**Terminated:** Jan 07, 2016



**KOREA**
**Cambodia-Korea, Republic BIT**
**Signed:** Feb 10, 1997
**In force:** Mar 12, 1997



**SINGAPORE**
**Cambodia-Singapre BIT**
**Signed:** Nov 04, 1996
**In force:** Feb 24, 2000



**CHINA**
**Cambodia-China BIT**
**Signed:** Jul 19, 1996
**In force:** Feb 01, 2000



**THAILAND**
**Cambodia-Thailand BIT**
**Signed:** Mar 29, 1995
**In force:** Apr 18, 1997



**MALAYSIA**
**Cambodia-Malaysia BIT**
**Signed:** Aug 17, 1994
**In force:** May 09, 1997

(Source: UNCTAD International Investment Agreements Navigator)

# ការត្រៀមខ្លួនរបស់កម្ពុជាសម្រាប់ កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាសិប)

តាត ពុធសូដាវី*
ចម និម្មល**

អត្ថបទជំនួយស្មារតីនេះបង្ហាញពីចំណុចចូល និងការត្រៀមខ្លួនរបស់កម្ពុជាសម្រាប់គោលនយោបាយអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ចជាតិ គោលនយោបាយពាណិជ្ជកម្ម និងយុទ្ធសាស្ត្រ នៅពេលដែលប្រទេសមួយនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាពិសេសកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាសិប)។

## ការអនុវត្តម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា

កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានកើនឡើងក្នុងរង្វង់ ៧,៧% ក្នុងមួយឆ្នាំក្នុងរយៈពេលជាងពីរទសវត្សរ៍ ចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០១៩[1]។ ទោះជាយ៉ាងណាក៏ដោយ ជំងឺរាតត្បាតកូវីដ-១៩ មានផលប៉ះពាល់អវិជ្ជមានលើកំណើនផលិតផលក្នុងស្រុកសរុបដែលបានធ្លាក់ចុះ -៣,១% ក្នុងឆ្នាំ២០២០ និងបានស្ទុះងើបឡើងវិញពី ៣,០% ក្នុងឆ្នាំ២០២១ ដល់៥,៣% ក្នុងឆ្នាំ២០២២ ហើយត្រូវបានគេរំពឹងថានឹងកើនឡើងនៅ ៦,៥% ក្នុងឆ្នាំ២០២៣។ អតិផរណាបានធ្លាក់ចុះពី៤,៧% ក្នុងឆ្នាំ២០២២ ដល់ ២,២% ក្នុងឆ្នាំ២០២៣។ កំណើនវិជ្ជមាននេះ បានមកពីការរួមចំណែកពីពន្ធលើផលិតផល ការឧបត្ថម្ភធនក្នុងកម្រិតតិចតួចជាងមុន សេវាកម្ម ឧស្សាហកម្ម និងកសិកម្ម[2]។

## កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាសិប)

កិច្ចព្រមព្រៀងអាសិបគឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មធំជាងគេបង្អស់។ កិច្ចព្រមព្រៀងនេះត្រូវបានចាប់ផ្តើមការចរចានៅខែវិច្ឆិកាឆ្នាំ២០១២ រវាងប្រជាជាតិអាស៊ាន និងដៃគូកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរបស់អាស៊ាន ហើយបានចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២២។ កិច្ចព្រមព្រៀងនេះគ្រប់ដណ្តប់លើពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម វិនិយោគ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស កម្មសិទ្ធិបញ្ញា ការប្រកួតប្រជែង ការដោះស្រាយវិវាទ និងជំពូកដទៃទៀត[3]។ កិច្ចព្រមព្រៀងអាសិបផ្តល់នូវក្របខណ្ឌពាណិជ្ជកម្ម ដើម្បីឆ្លើយតបទៅនឹងការគាំពារនិយមដែលបណ្តាលមកពីសកលភាវូបនីយកម្ម ជំងឺរាតត្បាតកូវីដ-១៩ និងបញ្ហាសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន។

- **កំណើនសេដ្ឋកិច្ច៖** កើនក្នុងចន្លោះ ២,០% - ៣,៨%
- **ប្រជាជនសរុប៖** ១៥ ៥៥២ ២១១ ក្នុងឆ្នាំ២០១៩ (NIS 2019)[4]
- **អត្រាមានការងារធ្វើ៖** កើនក្នុងចន្លោះ ៣,២% - ៦,២% (បុគ្គលិកធ្វើការដោយកម្លាំង)
- **វិស័យដែលទទួលបានប្រយោជន៍ច្រើនជាងគេ រួមមាន៖** កសិកម្ម ផលិតកម្ម សំណង់ សេវាកម្ម និងថែទាំ (Thangavelu et al, 2022)[5]

* ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម
** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

[1] World Bank. 2022b. "Cambodia's Overview." Accessed October 17, 2022. https://www.worldbank.org/en/country/cambodia/overview.

[2] Asian Development Bank. 2022. "Asian Development Outlook 2022: Mobilizing Taxes for Development." Accessed 07 April 2022. https://www.adb.org/sites/default/files/publication/784041/ado2022.pdf.

[3] https://asean.org/wp-content/uploads/2012/05/RCEP-Guiding-Principles-public-copy.pdf.

[4] https://www.nis.gov.kh/index.php/km/

[5] Thangavelu, Shandre (et al.). 2022. "Potential Impact of RCEP and Stractural Transformation on Cambodia." In Regional Comprehensive Economic Parternship (RCEP): Implications, Challenges and Future Growth of East Asia and ASEAN, edited by Fukunari Kimura, Shandre Thangavelu, and Dionisius Narjoko, 8.1-8.49, Indonesia, ERIA.

- **ការនាំចេញសរុបទៅប្រទេសសមាជិកអាសិប៖** ៣,២៨ ប៊ីលានដុល្លារអាម៉េរិក កើនឡើង១១% ក្នុងរយៈពេល៩ខែ (២០២១-២០២២) ក្នុងឆ្នាំ២០២២
- **ការនាំចូលពីប្រទេសសមាជិកអាសិប៖** ១៦,២៤ ប៊ីលានដុល្លារអាម៉េរិក កើនឡើង៩% ក្នុងរយៈពេល៩ខែ (២០២១-២០២២) ក្នុងឆ្នាំ២០២២
- **ចំណូលពន្ធ៖** កើនឡើងចន្លោះពី ២,០% - ៣,៩% (Thangavelu et al, 2022)។
- **តារាងទី១** ខាងក្រោមបង្ហាញថា កម្ពុជាបានទទួលអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាពិសេសកិច្ចព្រមព្រៀងអាសិប។ អត្រានៃការនាំចេញ និងនាំចេញក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ក្នុងចំណោមប្រជាជាតិអាស៊ាន និងប្រទេសសមាជិកអាសិប ក្នុងរយៈពេល៩ខែក្នុងឆ្នាំ២០២២នេះ មានការកើនឡើងបន្តិចម្តងៗ។

**តារាងទី១៖ អត្រានៃការធ្វើពាណិជ្ជកម្មរបស់កម្ពុជា ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី**

កិច្ចព្រមព្រៀងអាសិបចូលជាធរមាន ក្នុងរយៈពេល៩ខែ ឆ្នាំ២០២២ (គិតជាលានដុល្លារអាម៉េរិក)

| | ពិភពលោក | អាសិប | អាស៊ាន | អូស្ត្រាលី | ចិន | ជប៉ុន | កូរ៉េខាងត្បូង | នូវ៉ែលសេឡង់ |
|---|---|---|---|---|---|---|---|---|
| នាំចូល | 23,764(15%∆) | 19,363(12%∆) | 10,297(9%∆) | 121(51%∆) | 7,901(14%∆) | 602(27%∆) | 426(-3%▽) | 17(48%∆) |

កិច្ចព្រមព្រៀងអាសិបចូលជាធរមាន ក្នុងរយៈពេល៩ខែ ឆ្នាំ២០២២ (គិតជាលានដុល្លារអាម៉េរិក)

| | ពិភពលោក | អាសិប | អាស៊ាន | អូស្ត្រាលី | ចិន | ជប៉ុន | កូរ៉េខាងត្បូង | នូវ៉ែលសេឡង់ |
|---|---|---|---|---|---|---|---|---|
| នាំចេញ | 17,258(22%∆) | 4,703(6%∆) | 2,436(9%∆) | 284(133%∆) | 895(-18%▽) | 898(8%∆) | 175(21%∆) | 16(45%∆) |

ប្រភព៖ ក្រសួងពាណិជ្ជកម្ម (២០២២)

## តើអ្វីជាបញ្ហាប្រឈម និងឱកាសសំខាន់ៗសម្រាប់កម្ពុជាក្នុងការចូលអាសិប?

ទោះបីជាតួលេខខាងលើទាំងអស់បង្ហាញពីទស្សនវិស័យសេដ្ឋកិច្ចជាវិជ្ជមានសម្រាប់កម្ពុជាក៏ដោយ លោក Lee (2022) អះអាងថា ប្រទេសជាសមាជិកអាសិបផ្សេងគ្នា នឹងមិនទទួលបានអត្ថប្រយោជន៍ស្មើគ្នាពីការចូលរួមរបស់ពួកគេនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាពិសេសកិច្ចព្រមព្រៀងអាសិប[6]។

1. អត្ថប្រយោជន៍ត្រូវបានទទួលមិនស្មើភាពគ្នា និងលំអៀងទៅតាមកម្លាំងពលកម្មជំនាញ និងគ្មានជំនាញ។ ចំណូលប្រមាណ៧០%ដែលបានពីការធ្វើពាណិជ្ជកម្ម បានសម្រាប់តែក្រុមអ្នកមានចំណូលខ្ពស់ជាងគេប៉ុណ្ណោះ។
2. សមាហរណកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាប់ពាក់ព័ន្ធជាអវិជ្ជមានជាមួយនឹងការប្រឆាំងសកលភាវូបនីយកម្ម និងការគាំពារនិយម (Kimura et al. 2022)[7]។
3. អ្នកបង្កើតគោលនយោបាយ អ្នកចរចាពាណិជ្ជកម្ម អ្នកអនុវត្ត និងសហគ្រាសធុនតូច និងមធ្យមរបស់កម្ពុជា ប្រហែលជាមិនទាន់យល់ច្បាស់អំពីលក្ខណៈ ការប្តេជ្ញាចិត្ត និងផលប៉ះពាល់របស់កិច្ចព្រមព្រៀងអាសិប ជាពិសេសសមតុល្យពាណិជ្ជកម្មក្នុងវិស័យផ្សេងៗគ្នាដូចជា កសិកម្ម សំណង់ សេវាកម្ម និងវិស័យធនាគារ។

[6] Lee, Cassey. 2022. "Focus Areas and Support for Small and Medium-sized Enterprises." In *Dynamism of East Asia and RCEP: The Framework for Regional Integration*, edited by Fukunari Kimura, Shandre Thangavelu, Shujiro Urata, and Dionisius Narjoko, p. 277-298, Indonesia, ERIA.

[7] Kimura, Fukunari., (et al.). 2022. "Regional Comprehensive Economic Partnership (RECP): Challenges and Opportunities for ASEAN and East Asia." In Dynamism of East Asia and RCEP: The Framework for Regional Integration, edited by Fukunari Kimura, Shandre Thangavelu, Shujiro Urata, and Dionisius Narjoko, p. 1-11, Indonesia, ERIA.

4. ភាពខុសគ្នារវាងអាស៊ាន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មផ្សេងទៀតមានដូចជា សម្បទានពន្ធគយផ្សេងៗគ្នា ការចែករំលែករួមគ្នា ច្បាប់ប្រភពដើមតែមួយ បញ្ជីវិជ្ជមាន និងអវិជ្ជមានក្នុងសេរីភាវូបនីយកម្មសេវាកម្ម (Kimura, et al. 2022)[8]។

ទីបំផុត កម្ពុជាមិនទាន់ត្រៀមខ្លួនរួចរាល់ក្នុងការយល់ដឹងអំពីអត្រាលុបបំបាត់ពន្ធលើប្រទេសជាសមាជិកអាស៊ាន ដូចជា អាស៊ាន អូស្ត្រាលី ចិន ជប៉ុន កូរ៉េខាងត្បូង និងនូវែលសេឡង់នោះទេ។

## ការធ្វើចំណាត់ថ្នាក់នៃចំណុចចាប់ផ្ដើមរបស់កម្ពុជាក្នុងកិច្ចព្រមព្រៀងអាស៊ិប

| ល.រ. | ចំណុចចាប់ផ្ដើមរបស់កម្ពុជា | វិធានការក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងអាស៊ិប | | | |
|---|---|---|---|---|---|
| | | ការបណ្ដុះបណ្ដាលសមត្ថភាព និងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ | ការយល់ដឹងសាធារណៈ | ការស្រាវជ្រាវ និងនវានុវត្តន៍ក្នុងការធ្វើពាណិជ្ជកម្ម | ព័ត៌មានសម្រាប់ធុរកិច្ច |
| ១ | ការចែករំលែកព័ត៌មានអំពីភាពជោគជ័យរបស់កិច្ចព្រមព្រៀងអាស៊ិប | | | | x |
| ២ | ផ្ដោតអាទិភាពលើមុខទំនិញសំខាន់ៗ (ពាណិជ្ជកម្មទំនិញ) និងពាណិជ្ជកម្មសេវាកម្ម ដែលអាចអនុញ្ញាតឱ្យកម្ពុជាឈានជើងចូលទៅក្នុងទីផ្សារអន្តរជាតិបាន | x | | x | |
| ៣ | ការវាយតម្លៃពីភាពរួចរាល់សម្រាប់កិច្ចព្រមព្រៀងអាស៊ិប | | | x | |
| ៤ | បង្កើតក្របខណ្ឌគោលនយោបាយពាណិជ្ជកម្ម ដើម្បីដោះស្រាយការកើនឡើងនៃការគាំពារនិយម ដោយសារតែសកលភាវូបនីយកម្ម ជំងឺរាតត្បាតកូវីដ-១៩ និងសង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែន | x | | x | |
| ៥ | ការជំរុញផលប្រយោជន៍យុទ្ធសាស្ត្ររបស់កម្ពុជា | x | | x | |
| ៦ | ការជំរុញពាណិជ្ជកម្មតាមរយៈច្បាប់ពាណិជ្ជកម្មដែលមានភាពស៊ីសង្វាក់គ្នា | x | | | x |
| ៧ | ពិនិត្យមើលកាលានុវត្តភាពសម្រាប់កម្មវិធីផ្លាស់ប្ដូរបទពិសោធន៍រវាងសហគ្រិននៃប្រទេសនីមួយៗ | | x | | |
| ៨ | កាលានុវត្តភាពច្រកទីផ្សារថ្មី | | x | x | x |
| ៩ | កម្ពុជាគួរត្រៀមខ្លួនឱ្យបានរួចរាល់ក្នុងការស្វែងយល់ពីអត្រាពន្ធគយដែលលុបចោល ក្នុងចំណោមប្រទេសសមាជិកអាស៊ិប ដូចជាអាស៊ាន អូស្ត្រាលី ចិន ជប៉ុន កូរ៉េខាងត្បូង និងនូវែលសេឡង់ | x | | x | x |

ប្រភព៖ Lee, 2022 (p.289)

[8] Kimura, Fukunari., (et al.). 2022. Dynamism of East Asia and Regional Comprehensive Economic Partnership (RECP): The Framework for Regional Integration. Indonesia, ERIA.

# Cambodia's Readiness for RCEP

**TAT Puthsodary***
**CHAM Nimul****

This ***Special Edition*** presents Cambodia's entry points and readiness for national macroeconomic development policy, trade policy and strategies once the country enters into the Free Trade Agreements (FTAs), especially Regional Comprehensive Economic Partnership (RCEP).

## Cambodia's Macroeconomic Performance

Cambodia's the economic growth increased around 7.7 percent per annum for over two decades from 1998 to 2019[9]. However, the COVID-19 pandemic had a negative impact on the GDP growth which dropped at -3.1% in 2020, and rebounded from 3.0% in 2021 to 5.3% in 2022 and is expected to climb at 6.5% in 2023. The inflation dropped from 4.7% in 2022 to 2.2% in 2023. The positive growth results from the contributions from taxes on products less subsidies, services, industry and agriculture[10].

## Reginal Comprehensive Economic Partnership (RCEP)

The RCEP is the biggest free trade agreement. It was launched in November 2012 between the ASEAN nations and ASEAN's free trade agreement partners; and RCEP entered into force on 1 January 2022. It encompasses trade in goods, trade in services, investment, economic and technical cooperation, intellectual property, competition, dispute resolution and other issues[11]. RCEP offers a trade framework to address the rising protectionism due to globalization, COVID-19 pandemic and Russia-Ukraine war.

- GDP growth: 2.0%-3.8%
- Population: 15,552,211 in 2019 (NIS 2019)[12]
- Employment: 3.2% - 6.2% (blue-collar workers)
- The sectors benefit the most: Agriculture, manufacturing, construction, maintenance and services sector (Thagavelu et al, 2022)[13]
- Total export to RCEP countries: US$3.28 billion, increased by 11% as of 9 months in 2021-2022) in 2022
- RCEP market with Cambodia: US$ 16.24 billion (increased by 9%) in 2022
- Tax revenue: 2.0% - 3.9% (Thagavelu et al, 2022)
- **Figure 1** below demonstrates Cambodia has gained benefits from the FTAs, especially RCEP. The FTA coverage ratio of exports and exports among ASEAN nations and RCEP member countries within nine months in 2022 has increased gradually.

### Figure 1: FTA coverage ratio of Cambodian trade

RCEP enters into force (US$ million) in 9 months 2022

| | The world | RCEP | ASEAN | Australia | China | Japan | South Korea | New Zealand |
|---|---|---|---|---|---|---|---|---|
| Imports | 23,764 (15% Δ) | 19,363 (12% Δ) | 10,297 (9% Δ) | 121 (51% Δ) | 7,901 (14% Δ) | 602 (27% Δ) | 426 (-3% ∇) | 17 (48% Δ) |

* Advisor to the Ministry of Commerce
** Secretary of State, Ministry of Commerce

[9] World Bank. 2022b. "Cambodia's Overview." Accessed October 17, 2022. https://www.worldbank.org/en/country/cambodia/overview.

[10] Asian Development Bank. 2022. "Asian Development Outlook 2022: Mobilizing Taxes for Development." Accessed 07 April 2022. https://www.adb.org/sites/default/files/publication/784041/ado2022.pdf.

[11] https://asean.org/wp-content/uploads/2012/05/RCEP-Guiding-Principles-public-copy.pdf.

[12] https://www.nis.gov.kh/index.php/km/

[13] Thangavelu, Shandre (et al.). 2022. "Potential Impact of RCEP and Structural Transformation on Cambodia." In *Regional Comprehensive Economic Parternship (RCEP): Implications, Challenges and Future Growth of East Asia and ASEAN*, edited by Fukunari Kimura, Shandre Thangavelu, and Dionisius Narjoko, 8.1-8.49, Indonesia, ERIA.

RCEP enters into force (US$ million) in 9 months 2022

| Exports | The world | RCEP | ASEAN | Australia | China | Japan | South Korea | New Zealand |
|---|---|---|---|---|---|---|---|---|
| | 17,258 (22% Δ) | 4,703 (6% Δ) | 2,436 (9% Δ) | 284 (133% Δ) | 895 (-18% ∇) | 898 (8% Δ) | 175 (21% Δ) | 16 (45% Δ) |

Source: Ministry of Commerce, 2022

### What are key challenges and opportunities for Cambodia entering the RCEP?

Although all the above figures show a positive economic outlook for Cambodia, Lee (2022) argues that different RCEP countries will not gain equally from their participation in the free trade agreements (FTAs), particularly RCEP[14].

1. The benefits from trade have been unequally distributed and biased between skilled and unskilled workforces. Around 70% of the income generated from trade went to the top two high income groups.
2. The FTA integration is negatively implicated with anti-globalization and protectionism (Kimura et al. 2022)[15].
3. Cambodia's policy-makers, trade negotiators, practitioners and SMEs may not yet fully understand RCEP features, commitments, and impacts, especially trade balance in different sectors such as agriculture, construction, services and banking sector.
4. The differentiations between RCEP and other trade agreements such as different tariff concessions, co-sharing, single rule of origin, positive and negative lists in services liberalization (Kimura, et al. 2022)[16].

### Mapping of Cambodia's entry points

| No. | Cambodia's entry points | Measures under RCEP framework | | | |
|---|---|---|---|---|---|
| | | Capacity building and technical and financial assistance | Public awareness | Research and innovation in trade | Information for business |
| 1 | Information sharing on success stories of RCEP | | | | x |
| 2 | Prioritize key products (trade in goods) and trade in services that enable Cambodia to enter into international markets. | x | | x | |
| 3 | A RCEP readiness assessment | | | x | |

[14] Lee, Cassey. 2022. "Focus Areas and Support for Small and Medium-sized Enterprises." In *Dynamism of East Asia and RCEP: The Framework for Regional Integration*, edited by Fukunari Kimura, Shandre Thangavelu, Shujiro Urata, and Dionisius Narjoko, p. 277-298, Indonesia, ERIA.

[15] Kimura, Fukunari., (et al.). 2022. "Regional Comprehensive Economic Partnership (RECP): Challenges and Opportunities for ASEAN and East Asia." In *Dynamism of East Asia and RCEP: The Framework for Regional Integration*, edited by Fukunari Kimura, Shandre Thangavelu, Shujiro Urata, and Dionisius Narjoko, p. 1-11, Indonesia, ERIA.

[16] Kimura, Fukunari., (et al.). 2022. *Dynamism of East Asia and Regional Comprehensive Economic Partnership (RECP): The Framework for Regional Integration*. Indonesia, ERIA.

| | | | | | |
|---|---|---|---|---|---|
| 4 | Develop trade policy framework to address the rising protectionism due to globalization, COVID-19 pandemic and Russia-Ukraine war | x | | x | |
| 5 | Advancement of Cambodia's strategic interests | x | | x | |
| 6 | Trade facilitation through great coherence of trade rules | x | | | x |
| 7 | Explore opportunities for exchanges of experiences among Parties' entrepreneurial programs | | x | | |
| 8 | New market access opportunities | | x | x | x |
| 9 | Cambodia should be ready to comprehend tariff elimination rates on RCEP member countries such as ASEAN, Australia, China, Japan, South Korea and New Zealand | x | | x | x |

Source: Lee, 2022 (p.289)

# ថាមវន្តថ្មីនៃតំបន់អាស៊ីបូព៌ា និងអាស៊ាន៖ ស្ថាប័នពាណិជ្ជកម្មថ្មីនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងគោលការណ៍រស់ នៃកិច្ចព្រមព្រៀងអាសិប

ដោយ៖ **សនជ្រេ មូហ្គាន ថាងកាវ៉ាលូ**[17]
វិទ្យាស្ថាន Jeffrey Cheah សម្រាប់អាស៊ីអាគ្នេយ៍ សាកលវិទ្យាល័យសាន់វ៉េយ៍

## ១. សេចក្តីផ្តើម

អស់រយៈពេលមួយទសវត្សរ៍កន្លងមកនេះ តំបន់អាស៊ីបូព៌ាបាននិងកំពុងប្រឈមមុខនឹងការកើនឡើងនូវលទ្ធិគាំពារនិយម និងការប្រឆាំងនឹងសកលភាវូបនីយកម្មក្នុងពាណិជ្ជកម្មតំបន់ និងពិភពលោក ដែលនឹងជះឥទ្ធិពលយ៉ាងធំធេងលើកំណើន និងការអភិវឌ្ឍក្នុងតំបន់។ វិបត្តិនៃជំងឺរាតត្បាតកូវីដ-១៩ ភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាម៉េរិកនិងចិន សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន សម្ពាធអតិផរណាសកល ការរំខាននៃខ្សែច្រវាក់តម្លៃសកល (GVC) និងការរំពឹងទុកនៃការធ្លាក់ចុះសេដ្ឋកិច្ចសកល និងតំបន់នៅឆ្នាំ២០២៣ នឹងមានផលប៉ះពាល់យ៉ាងខ្លាំងលើការអភិវឌ្ឍក្នុងតំបន់រយៈពេលខ្លី និងរយៈពេលវែង។ ជាមួយនឹងភាពមិនប្រាកដប្រជាដែលកំពុងកើនឡើងជាសកល និងការរំខានដល់ច្រវាក់តម្លៃសកល ពិភពលោកនឹងជួបប្រទះនូវគោលនយោបាយផ្តោតមកខាងក្នុងស្រុក ការកើនឡើងនៃនយោបាយគាំពារនិយម និងការបែកខ្ញែកនៃរចនាសម្ព័ន្ធពាណិជ្ជកម្មសកល និងតំបន់។ ទោះជាយ៉ាងណា ពាណិជ្ជកម្ម និងខ្សែច្រវាក់តម្លៃសកល មានសារសំខាន់សម្រាប់ការស្តារឡើងវិញក្រោយជំងឺរាតត្បាត ប្រកបដោយនិរន្តរភាព និងបរិយាប័ន្ន ដើម្បីកាត់បន្ថយភាពក្រីក្រ និងសម្រាប់ការបង្កើតដំណើរការស្តារឡើងវិញប្រកបដោយចីរភាព និងភាពធន់នៅក្នុងលក្ខខណ្ឌនៃបរិវត្តកម្មបៃតង និងឌីជីថលនៃពាណិជ្ជកម្មតំបន់។

ការសិក្សាថ្មីៗដោយលោក គីម៉ុយរ៉ា បានគូសបញ្ជាក់ពីសារសំខាន់នៃការបញ្ជាទិញពាណិជ្ជកម្មអន្តរជាតិដោយផ្អែកលើមូលដ្ឋានច្បាប់ដែលជាលក្ខខណ្ឌសំខាន់សម្រាប់ដំណើរការប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលនៃបណ្តាញផលិតកម្មអន្តរជាតិ (IPNs) នៅតំបន់អាស៊ីបូព៌ា។ ដំណើរការផលិតកម្មនៅក្នុងខ្សែច្រវាក់តម្លៃផលិតកម្មសកល ដែលមានទីតាំងនៅក្រៅប្រទេស ទាមទារនូវការសម្របសម្រួលយ៉ាងជិតស្និទ្ធនៃលំហូរទំនិញ និងសេវាកម្មកម្រិតមធ្យម ដែលចាំបាច់ត្រូវតែមានប្រព័ន្ធពាណិជ្ជកម្មផ្អែកលើច្បាប់ ដែលអនុញ្ញាតឱ្យមានសកម្មភាពខ្សែច្រវាក់តម្លៃសកល ដែលមានស្ថិរភាព និងមានថាមវន្តនៅក្នុងតំបន់។ ទោះជាយ៉ាងណា ប្រព័ន្ធពាណិជ្ជកម្មផ្អែកលើច្បាប់បានចុះខ្សោយជាងមួយទសវត្សរ៍កន្លងមកនេះ ដោយសារតែសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាម៉េរិកនិងចិន និងភាពទន់ខ្សោយរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងការគាំទ្រដល់ប្រព័ន្ធពាណិជ្ជកម្មសកលបច្ចុប្បន្ន ដែលធ្វើឱ្យកាន់តែរ៉ាំរ៉ៃបន្ថែមដោយការជាប់គាំងនៃអង្គ ឧទ្ធរណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក។ លើសពីភាពមិនប្រាកដប្រជាជាសកល និងវិបត្តិនៃជំងឺរាតត្បាត ពិភពលោកក៏មានសម្ពាធខ្លាំងលើការបង្កើតតំបន់ពាណិជ្ជកម្ម និងរចនាសម្ព័ន្ធពាណិជ្ជកម្ម ដើម្បីគ្រប់គ្រងបញ្ហាសំខាន់ៗ ក្នុងស្រុក និងតំបន់ លើសពីបញ្ហាពាណិជ្ជកម្មបែបប្រពៃណីដែលទាក់ទងតែលំហូរទំនិញ សេវាកម្ម និងមូលធន។ វេទិកាកម្រិតខ្ពស់ ដែលរៀបចំដោយក្រសួងពាណិជ្ជកម្មកម្ពុជា លេខាធិការដ្ឋានអាស៊ាន និងវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចតំបន់អាស៊ាននិងអាស៊ីបូព៌ា ស្តីពីកិច្ចព្រមព្រៀងអាសិប និងថាមវន្តក្នុងតំបន់ បានគូសបញ្ជាក់ពីរបៀបវារៈសេដ្ឋកិច្ច

[17] គោលនយោបាយសង្ខេបនេះគឺជាផ្នែកមួយនៃសុន្ទរកថាគន្លឹះថ្លែងនៅវេទិកាថ្នាក់រដ្ឋមន្ត្រីអាស៊ាន កាលពីកិច្ចប្រជុំកំពូលអាស៊ាន នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ២០២២ នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា។

និងសង្គមថ្មី ដែលរចនាសម្ព័ន្ធពាណិជ្ជកម្មត្រូវតែដោះស្រាយលើសពីបញ្ហាពាក់ព័ន្ធនឹងពាណិជ្ជកម្ម [18]។ វេទិកាបានលើកឡើងពីបញ្ហាដូចខាងក្រោម៖ (ក) បញ្ហាបរិស្ថាន និងការប្រែប្រួលអាកាសធាតុ (ខ) ឌីជីថលភាវូបនីយកម្ម និងផលប៉ះពាល់សង្គម (គ) ការកសាងសមត្ថភាពក្នុងស្រុកទាក់ទងនឹងការអភិវឌ្ឍ និងបណ្តុះបណ្តាលជំនាញ (ឃ) ខ្សែច្រវាក់តម្លៃសកល និងការកើនឡើងតួនាទីរបស់សហគ្រាសធុនតូច និងមធ្យម (ង) ការពង្រឹងវិធានមូលដ្ឋានពាណិជ្ជកម្ម និង (ច) និរន្តរភាព និងកំណើនប្រកបដោយបរិយាប័ន្នក្នុងតំបន់។ អ្នកចូលរួមជាន់ខ្ពស់ក៏បញ្ជាក់ពីតម្រូវការក្នុងការគិតគូដល់បញ្ហាបន្ថែមនៅក្នុងកិច្ចព្រមព្រៀងអាសិប ដែលជាកិច្ចព្រមព្រៀងរស់ (living) ផងដែរ។

តម្រូវការខាងលើទាមទារឱ្យមានរបៀបវារៈសេដ្ឋកិច្ច និងសង្គមថ្មី ក្រៅពីរចនាសម្ព័ន្ធពាណិជ្ជកម្ម និងតម្រូវការក្នុងការសម្របរវាងគោលនយោបាយសកល តំបន់ និងក្នុងស្រុក និងបញ្ហារចនាសម្ព័ន្ធ។ តម្រូវការនេះក៏ទាមទារឱ្យមានការសម្របសម្រួលនៅក្នុងប្រទេស និងរវាងបណ្តាប្រទេសនានា និងរវាងរចនាសម្ព័ន្ធពាណិជ្ជកម្មផ្សេងៗគ្នាផងដែរ ដើម្បីកាត់បន្ថយឥទ្ធិពលត្រួតស៊ីគ្នានៃគោលនយោបាយ តម្លៃប្រតិបត្តិការខ្ពស់ក្នុងពាណិជ្ជកម្មតាមព្រំដែន និងការបែកខ្ញែកនៃក្របខ័ណ្ឌពាណិជ្ជកម្មសកល និងតំបន់។ ការណ៍នេះបង្ហាញពីតម្រូវការបន្ទាន់ក្នុងការឱ្យមានស្ថាប័នពាណិជ្ជកម្មថ្មីៗ ដែលទាមទារឱ្យមានការត្រួតពិនិត្យបន្ថែមទៀតលើគោលនយោបាយពាណិជ្ជកម្មស្តីពីបញ្ហាសេដ្ឋកិច្ច និងសង្គមនៅក្នុងស្រុក តំបន់ និងសកល។

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាសិប ដែលជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដ៏ធំបំផុតនៅលើពិភពលោកចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០២២ ត្រូវបានគេរំពឹងថា នឹងផ្តល់នូវក្របខ័ណ្ឌស្ថាប័នថ្មី ដែលជាសមាសធាតុផ្នែកស្ថាប័នដែលអាចបញ្ចូលក្នុងកិច្ចព្រមព្រៀងអាសិប សម្រាប់សេរីភាវូបនីយកម្មដែលមានវឌ្ឍនភាព នៃពាណិជ្ជកម្មតំបន់ និងសកល ហើយក៏ដើម្បីដោះស្រាយបញ្ហាបច្ចុប្បន្ន ដែលហួសពីកិច្ចការពាណិជ្ជកម្មនិងវិនិយោគ។

## ២. អាសិបគឺជាកិច្ចព្រមព្រៀងរស់៖ ស្ថាប័នពាណិជ្ជកម្មថ្មីនៅក្នុងកិច្ចព្រមព្រៀងពហុភាគី

អាសិបគឺជាប្លុកពាណិជ្ជកម្មសេរីសកលដ៏ធំបំផុតនៅលើពិភពលោកដែលមានចំនួនប្រជាជនសរុបចំនួន ២,២ ប៊ីលាននាក់ (៣០% នៃចំនួនប្រជាជនពិភពលោក) ផលិតផលក្នុងស្រុកសរុបក្នុងតំបន់(GDP) ប្រមាណ៣៨,៨១ ទ្រីលានដុល្លារ (៣០% នៃផលិតផលក្នុងស្រុកសរុបពិភពលោកក្នុងឆ្នាំ ២០១៩) និងជិត ២៨% នៃពាណិជ្ជកម្មសកល។ កិច្ចព្រមព្រៀងនេះកំណត់របៀបវារៈដ៏សំខាន់មួយសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគ ក្នុងកិច្ចការពាណិជ្ជកម្មសកល ដែលរួមមានការបើកទីផ្សារក្នុងស្រុកដ៏ធំ (តម្រូវការ) ការបញ្ចេញធនធានដ៏ធំសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគ និងការបង្កើតសកម្មភាពខ្សែច្រវាក់តម្លៃក្នុងតំបន់និងសកលប្រកបដោយថាមវន្ត។

លក្ខណៈពិសេសសំខាន់ៗមួយចំនួននៃអាសិបមានដូចជា៖ (ក) ក្របខ័ណ្ឌវិធានប្រភពដើមតែមួយសម្រាប់ប្រទេសសមាជិកទាំង១៥ ដែលអាចមានការពន្លឿន និងបង្កើនឥទ្ធិពលលើខ្សែច្រវាក់តម្លៃសកលនៅក្នុងតំបន់, (ខ) ជាតុសំខាន់នៃឥទ្ធិពលនៃការចូលរួមរបស់ចិន-ជប៉ុន-កូរ៉េ (CJK) ដោយសារកិច្ចព្រមព្រៀងអាសិប គឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដំបូងសម្រាប់ពាណិជ្ជកម្ម និងវិនិយោគក្នុងចំណោមប្រទេសទាំងនេះ, (គ) ជាតុចាំបាច់នានាសម្រាប់បរិវត្តកម្មឌីជីថល និងសេរីភាវូបនីយកម្មសេវាក្នុងពាណិជ្ជកម្មសេវាសំខាន់ៗរួមមានពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហិរញ្ញវត្ថុ សេវាកម្មវិជ្ជាជីវៈ និងទូរគមនាគមន៍, (ឃ) មជ្ឈភាពអាស៊ាន, និង (ង) អាសិបជាកិច្ចព្រមព្រៀងរស់។

[18] The High-Level Forum on RCEP, 'RCEP 10th-Year Anniversary: Reminiscing the Journey of RCEP and Launching of ERIA Second Book: Dynamism of East Asia and Regional Comprehensive Economic Partnership (RCEP): The Framework for Regional Integration' on 2-3 November 2022 at Phnom Penh, Cambodia. https://www.eria.org/events/rcep-10-year-anniversary-reminiscing-the-journey-of-rcep-and-launching-of-eria-book-dynamism-of-east-asia-and-regional-comprehensive-economic-partnership-rcep-the-framewo/

លក្ខណៈស្ថាប័នសំខាន់នៃអាសិប គឺបញ្ញត្តិស្ថាប័នដែលមានចែងក្នុងជំពូកទី ១៨ នៃកិច្ចព្រមព្រៀងនេះ ដែលបង្កើតទស្សនវិស័យវែងឆ្ងាយសម្រាប់សេរីភាវូបនីយកម្មពាណិជ្ជកម្មដែលកំពុងរីកចម្រើន និងដោះស្រាយបញ្ហាសេដ្ឋកិច្ច និងសង្គមសំខាន់ៗក្រៅពីពាណិជ្ជកម្ម។ នៅក្រោមជំពូកទី ១៨ (បញ្ញត្តិស្ថាប័ន) នៃកិច្ចព្រមព្រៀងអាសិប គណៈកម្មាធិការចម្រុះអាសិប (RJC) នឹងជួបប្រជុំគ្នាក្នុងរយៈពេល ១ ឆ្នាំបន្ទាប់ពីកិច្ចព្រមព្រៀងចូលជាធរមាន ហើយលេខាធិការដ្ឋានអាសិប នឹងសម្របសម្រួលកិច្ចប្រជុំទាំងអស់បន្ទាប់ពីនោះ។ លក្ខណៈពិសេសតែមួយគត់នៃអាសិប ដែលបង្កើតស្ថាប័ន "ស្ថាបនា" ក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីពហុភាគី នឹងបង្កើតជារបៀបវារៈថ្មីសម្រាប់ការអភិវឌ្ឍបណ្តុំស្ថាប័នពាណិជ្ជកម្មបន្តបន្ទាប់ទៀត នៅក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីពហុភាគី ដែលនឹងសម្របការកែទម្រង់ក្នុងស្រុក និងតំបន់ ដើម្បីពង្រីកឱ្យទូលំទូលាយនៃផលប្រយោជន៍សេដ្ឋកិច្ច និងសង្គម លើសពីពាណិជ្ជកម្មដែលផ្អែកលើមូលដ្ឋានច្បាប់ ។ មកទល់ពេលនេះ មិនទាន់មានកិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគីណាផ្សេងទៀតឡើយ រួមទាំងកិច្ចព្រមព្រៀងភាពជាដៃគូអន្តរប៉ាស៊ីហ្វិកគ្រប់ជ្រុងជ្រោយ និងមានវឌ្ឍនភាព (CPTPP) ដែលផ្តល់ការបង្កើតស្ថាប័នស្ថាបនា និងលេខាធិការដ្ឋានដូចកិច្ចព្រមព្រៀងអាសិប បើទោះបីជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមួយចំនួនដូចជា AANZFTA និង AHKFTA បានបង្កើតការិយាល័យនៅលេខាធិការដ្ឋានអាស៊ានដើម្បីបង្កើនធនធានមនុស្ស និងគាំទ្រដល់គណៈកម្មាធិការចម្រុះក្នុងការត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរបស់ពួកគេជាមួយអាស៊ានក៏ដោយ។ បទប្បញ្ញត្តិនៅក្រោមកិច្ចព្រមព្រៀងអាសិប ក៏ពង្រឹងមជ្ឈភាពអាស៊ាន និងបង្កើតរបៀបវារៈឆ្ពោះទៅមុខសម្រាប់អាស៊ាន ដើម្បីបង្កើតកំណើនប្រកបដោយចីរភាព និងបរិយាប័ន្ននៅក្នុងតំបន់។

ក្នុងនាមជាកិច្ចព្រមព្រៀងរស់ គណៈកម្មាធិការចម្រុះអាសិប នឹងអាចបង្កើតរបៀបវារៈសមាហរណកម្មតំបន់កាន់តែទូលំទូលាយដើម្បីដោះស្រាយបញ្ហាបច្ចុប្បន្នសំខាន់ៗដូចជា បរិស្ថាននិងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍជំនាញ បរិវត្តកម្មបៃតង និងការអភិវឌ្ឍមជ្ឈមណ្ឌលទីក្រុងឌីជីថល និងឆ្លាតវៃ។ តួនាទីរបស់លេខាធិការដ្ឋានអាសិបក្នុងនាមជាស្ថាប័នឯករាជ្យ និងមានវឌ្ឍនភាពនឹងមានសារសំខាន់ក្នុងការអនុវត្ត ត្រួតពិនិត្យ វាយតម្លៃ និងប្រើប្រាស់សមាសធាតុឆ្ពោះទៅមុខនៃកិច្ចព្រមព្រៀងរស់នេះ។ លេខាធិការដ្ឋានអាសិបនឹងបង្កើតការបំពេញបន្ថែមនៅក្នុងគោលនយោបាយជាមួយលេខាធិការដ្ឋានអាស៊ាន ប្រមូលធនធានបន្ថែមទៀត ហើយនឹងមានសមាសធាតុស្ថាប័នថ្មីៗ ដើម្បីដោះស្រាយភាពមិនច្បាស់លាស់ជាសកលដែលកំពុងកើនឡើង និងបញ្ហាប្រឈមថ្មីៗដែលកំពុងកើតឡើង។

## ៣. សារសំខាន់នៃអាសិប ក្នុងកំណើនប្រកបដោយនិរន្តរភាព និងបរិយាប័ន្នក្នុងយុគសម័យក្រោយជំងឺរាតត្បាត

កិច្ចព្រមព្រៀងអាសិបគឺជាក្របខ័ណ្ឌដ៏សំខាន់មួយសម្រាប់តំបន់នីយកម្ម និងពាណិជ្ជកម្មសកល ក្នុងបរិបទនៃភាពមិនប្រាកដប្រជាបច្ចុប្បន្ន និងគោលនយោបាយផ្តោតមកខាងក្នុងស្រុក ដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ-១៩ និងសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាម៉េរិក និងចិន។ កិច្ចព្រមព្រៀងនេះផ្តល់ជាកម្លាំងចលករដ៏សំខាន់សម្រាប់ពាណិជ្ជកម្ម និងការវិនិយោគសកល ហើយប្តូរពីសកម្មភាពក្នុងស្រុក និងក្នុងតំបន់អាស៊ីប៉ូស៊ីហ្វិក ទៅជាតំបន់នីយកម្ម និងពាណិជ្ជកម្មនិងវិនិយោគសកល ដែលបើកចំហ។

ផលប៉ះពាល់នៃកិច្ចព្រមព្រៀងអាសិប នឹងមានសារសំខាន់សម្រាប់អាស៊ាន និងប្រទេសដែលមានការអភិវឌ្ឍតិចតួច (LDCs)។ ការវិភាគតាមរូបមន្ត CGE ដោយលោក Itakura បានគូសបញ្ជាក់ពីផលប៉ះពាល់ជាវិជ្ជមាននៃកិច្ចព្រមព្រៀងអាសិបលើ GDP សម្រាប់សមាជិកអាសិបទាំងអស់ពេញមួយទសវត្សរ៍ឆ្នាំ២០៣០ ជាពិសេសក្នុងសេណារីយ៉ូដែលមានកិច្ចសម្រួលពាណិជ្ជកម្ម និងវិនិយោគដែលស៊ីជម្រៅ និងការដោះស្រាយបញ្ហាមិនមែនព្រំដែន (S4៖ ការកាត់បន្ថយពន្ធគយ សេរីភាវូបនីយកម្មសេវា ការកែលម្អភ័ស្តុភារ និងកិច្ចសម្រួលការវិនិយោគ)។ លោក Park បានគូសបញ្ជាក់ថា កិច្ចព្រមព្រៀងអាសិបនឹងបង្កើតផលចំណេញច្រើនជាងកិច្ចព្រមព្រៀង CPTPP សម្រាប់ប្រទេសសមាជិកអាសិប ។

## ៤. ផលប៉ះពាល់នៃអាសិបក្នុងការបង្កើតសមាហរណកម្មប្រកបដោយនិរន្តរភាព និងបរិយាប័ន្ន

